ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥០ អនក្រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិសម្របសម្រួលលើវិស័យពិការភាព

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០១ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្មមាត្រា ៤ មាត្រា ១០ និងមាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ១០០ អនក្រ/បក ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០០៥ ស្តីពី វិសោធនកម្ម ជំពូកទី ៤ ជំពូកទី ៥ ជំពូកទី ៦ ជំពូកទី ៧ ជំពូកទី ៨ ជំពូកទី ១៣ និងជំពូកទី ១៥ នៃអនុក្រឹត្យលេខ ៧៦ អនក្រ/បក ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ/បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលសំរាប់ការអភិវឌ្ឍន៍ជាតិលើវិស័យពិការភាព

Downloaded from http://www.khmerlaws.com

# សម្រេច

**ប្រការ ១ :**

បង្កើត **គណៈកម្មាធិការជាតិសម្របសម្រួលលើវិស័យពិការភាព** មានអក្សរកាត់ថា “ **គ.ជ.ស.ព** ” ជាភាសាអង់គ្លេស NATIONAL DISABILITY COORDINATION COMMITTEE មានអក្សរកាត់ថា “ NDCC ” ដែលមានបេសកកម្ម ពិនិត្យតាមដាន សម្របសម្រួល វាយតម្លៃ និងជំរុញលើការងារអនុវត្តផែនការសកម្មភាពជាតិ ស្តីពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារមីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម និងបញ្ហាសំខាន់ៗ ពាក់ព័ន្ធនឹងពិការភាព។

**ប្រការ ២ :**

**គ.ជ.ស.ព** មានសមាសភាព៖

| | | |
|---|---|---|
| ១- រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | ជាប្រធាន |
| ២- អគ្គលេខាធិការ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន | | ជាអនុប្រធាន |
| ៣- រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | ជាអនុប្រធាន |
| ៤- អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល | ០១ រូប | ជាសមាជិក |
| ៥- អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ០១ រូប | ជាសមាជិក |
| ៦- អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និង កីឡា | ០១ រូប | ជាសមាជិក |
| ៧- អនុរដ្ឋលេខាធិការ ក្រសួងផែនការ | ០១ រូប | ជាសមាជិក |
| ៨- អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | ០១ រូប | ជាសមាជិក |
| ៩- អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១ រូប | ជាសមាជិក |
| ១០- នាយក ក្រុមប្រឹក្សាសកម្មភាពជនពិការ | ០១ រូប | អ្នកសម្របសម្រួល |
| ១១- នាយក មជ្ឈមណ្ឌលជាតិសំរាប់ជនពិការ | ០១ រូប | ជាសមាជិក |
| ១២- នាយក អង្គការជនពិការកម្ពុជា | ០១ រូប | ជាសមាជិក |
| ១៣- តំណាងដៃគូអភិវឌ្ឍន៍ | ០១ រូប | ជាសមាជិក |
| ១៤- តំណាងទីភ្នាក់ងារអង្គការសហប្រជាជាតិ | ០១ រូប | ជាសមាជិក |
| ១៥- ប្រធាននៃអនុគណៈកម្មាធិការជំនាញទាំងប្រាំមួយ | ០៦ រូប | ជាសមាជិក។ |

Downloaded from http://www.khmerlaws.com

ប្រការ ៣ :

ក្រុមប្រឹក្សាសកម្មភាពជនពិការ **ក.ស.ជ** ជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ សម្របសម្រួលលើវិស័យពិការភាព និងជាអនុគណៈកម្មាធិការជំនាញនានា ដែលមានទីតាំងនៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ប្រការ ៤ :

**គ.ជ.ស.ព** ត្រូវបើកអង្គប្រជុំយ៉ាងតិចមួយដងក្នុងរយៈពេលបីខែ។ បើចាំបាច់គណៈកម្មាធិការនេះ អាចបើកអង្គប្រជុំបានគ្រប់ពេល តាមការអញ្ជើញរបស់ប្រធាន ឬលេខាធិការដ្ឋាន។

**គ.ជ.ស.ព** ប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬលេខាធិការដ្ឋាន។

ប្រការ ៥ :

**គ.ជ.ស.ព** មានភារកិច្ចដូចខាងក្រោម ៖

- ពិនិត្យតាមដាន សម្របសម្រួល វាយតម្លៃ និងជំរុញលើការអនុវត្តន៍ផែនការសកម្មភាពជាតិស្តីពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារមីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ឆ្នាំ ២០០៩-២០១១។
- បង្កើតគោលនយោបាយនានា ដើម្បីកែលំអការសម្របសម្រួលវិស័យពិការភាព និងការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព។
- គាំទ្រ និងសហប្រតិបត្តិការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីបង្កើតនូវគោលនយោបាយនានា នៃការបញ្ចូលពិការភាព និងសេវាកម្មទៅក្នុងគ្រប់វិស័យទាំងអស់។
- ទំនាក់ទំនងជាមួយនិងក្រសួងពាក់ព័ន្ធ អង្គការផ្តល់សេវាកម្ម និងភ្នាក់ងារម្ចាស់ជំនួយនានា ដើម្បីផលប្រយោជន៍ដល់ជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារមីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម។
- ប្រមូលរបាយការណ៍ពីសកម្មភាព និងកម្មវិធីនានាលើវិស័យពិការភាព ពីបណ្តាក្រសួងពាក់ព័ន្ធ អង្គការផ្តល់សេវាកម្មនានា អនុគណៈកម្មការ និងភ្នាក់ងារដទៃទៀត។
- ជួយបំពេញកាតព្វកិច្ចចំពោះមជ្ឈដ្ឋានអន្តរជាតិ រួមបញ្ចូលអនុសញ្ញាស្តីពីការហាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ និង ពិធីសារបន្ថែម ក្រោយពីព្រះរាជាណាចក្រកម្ពុជាផ្តល់សច្ចាប័ន។
- ជួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តន៍ច្បាប់ស្តីពីកិច្ចការពារ និងការលើកកំពស់សិទ្ធិជនពិការ ដែលត្រូវបានអនុម័ត ។
- ជួយធ្វើការកំណត់ និងកៀងគរប្រភពធនធាននានាសម្រាប់សកម្មភាពវិស័យពិការភាព រួមបញ្ចូលកិច្ចសង្គ្រោះជនរងគ្រោះដោយសារមីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម។

Downloaded from http://www.khmerlaws.com

- ពិនិត្យតាមដាន សម្របសម្រួល វាយតម្លៃ និងសម្រេចលើបទដ្ឋានការងាររបស់អនុគណៈកម្មាធិការនីមួយៗ ។
- ឆ្លើយតបចំពោះការផ្តល់អនុសាសន៍នានារបស់អនុគណៈកម្មាធិការ ។

**ប្រការ ៦ :**

**គ.ជ.ស.ព** អាច ៖

- បង្កើតអនុគណៈកម្មាធិការជំនាញមួយចំនួនដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្លួនតាមការចាំបាច់ ។
- សមាសភាព និងភារកិច្ចរបស់អនុគណៈកម្មាធិការជំនាញនីមួយៗត្រូវកំណត់ដោយបទដ្ឋានការងារដោយឡែក ដែលសម្រេចដោយប្រធាននៃ **គ.ជ.ស.ព** ។

**ប្រការ ៧ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អគ្គលេខាធិការអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២ និង ៧*
- *រាជកិច្ច*
- *ឯកសារ -កាលប្បវត្តិ*

Downloaded from http://www.khmerlaws.com